ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ១០១៦ អក
ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៥
សាលក្រមលេខ៖ ១៦ (៨៨)
ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៦

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្ដាល**

-បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ វេលាម៉ោង ០២:៣០ នាទីរសៀល ដែលមានសមាសភាពចូលរួមជំនុំជម្រះដូចខាងក្រោម៖

**ចៅក្រមជំនុំជំរះ**

លោក [redacted] ប្រធានសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**

លោក [redacted] មេធាវីការពារសិទ្ធិឱ្យឈ្មោះ ខៀវ កែវពុទ្ធិ
លោកស្រី [redacted] មេធាវីការពារសិទ្ធិឱ្យឈ្មោះ ហួរ ម៉ាហ្គោ
លោក [redacted]ធីរៈ មេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] សៀងលី, ឈ្មោះ[redacted]សុជាន់ណា, ឈ្មោះ[redacted]ការម្យ, ឈ្មោះ[redacted] ស៊ីណា

-ដើម្បីជំនុំជំម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ១០១៦ អក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៥ ដែលមានជនជាប់ចោទដូចខាងក្រោម៖

១- ឈ្មោះ [redacted] ហេងចាន់វដ្ឋា ហៅ ដា ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ សិស្ស មានទីកន្លែងកំណើតនៅភូមិបោះអង្កាញ់ ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្ដាល និងបច្ចុប្បន្ននៅភូមិ[redacted]ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ[redacted] (រ) នៅលើរ ទោសដោយតុលាការ គ្មាន។ (ឃុំខ្លួនថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៥)

២- ឈ្មោះ [redacted] ហៅតាំង ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ មានទីកន្លែងកំណើត និងបច្ចុប្បន្ននៅ[redacted]ខេត្តកណ្ដាល មានឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (រ) នៅលើរ ទោសដោយតុលាការ គ្មាន។(ឃុំខ្លួនថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៥)

៣- ឈ្មោះ[redacted]កាណាន់ ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ មានទីកន្លែង[redacted] ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល និងបច្ចុប្បន្នស្នាក់នៅផ្ទះសំណាក់ [redacted] មានឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) នៅលើរ ទោសដោយតុលាការ គ្មាន។(ឃុំខ្លួនថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៥)៉



Scanned by CamScanner

៤- ឈ្មោះ: [redacted] ស៊ីណា ហៅ ស្រីខូច ភេទស្រី អាយុ ១៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ មានទីកន្លែងកំណើត [redacted] ស្រុកតាខ្មៅ ខេត្តកណ្តាល និងបច្ចុប្បន្ននៅភូមិដើមគរ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល មានឪពុកឈ្មោះ: [redacted] (រ) ម្តាយឈ្មោះ: [redacted] (រ) នៅលីវ ទោសដោយតុលាការ គ្មាន។(ឃុំខ្លួនថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៥)

ជាប់ចោទពីបទះ លួច ប្រព្រឹត្តនៅមាត់ទន្លេតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥, ប្រព្រឹត្តនៅភូមិស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ និងបទ សមគំនិតក្នុងអំពើលួច ប្រព្រឹត្តនៅម្តុំផ្សារព្រែកតូច ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ២៩, មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

៥-ឈ្មោះ: [redacted] ភារម្យ ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ មានទីកន្លែងកំណើតនៅ [redacted] ខេត្តកណ្តាល និងបច្ចុប្បន្ននៅភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល មានឪពុកឈ្មោះ: [redacted] (រ) ម្តាយឈ្មោះ: [redacted] (រ) នៅលីវ ទោសដោយតុលាការ គ្មាន។(ឃុំខ្លួនថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៥)

ជាប់ចោទពីបទះ លួច ប្រព្រឹត្តនៅមាត់ទន្លេតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥, ប្រព្រឹត្តនៅភូមិស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥, ប្រព្រឹត្តនៅភូមិដើមគរ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ និងបទ សមគំនិតក្នុងអំពើលួច ប្រព្រឹត្តនៅម្តុំផ្សារព្រែកតូច ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ២៩, មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

៦- ឈ្មោះ: [redacted] សាមិត ហៅ បាភាំង ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរ លាងម៉ូតូ មានទីកន្លែងកំណើត និងបច្ចុប្បន្ននៅ [redacted] ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល មានឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ: [redacted] (ស) នៅលីវ ទោសដោយតុលាការ គ្មាន។(ឃុំខ្លួនថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៥)

៧- ឈ្មោះ [redacted] សុជាន់ណា ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ មុខរបរ លក់កាហ្វេ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល និងបច្ចុប្បន្ននៅភូមិក្រពាំងអំពិល ឃុំក្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មានឪពុកឈ្មោះ: [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសដោយតុលាការ គ្មាន។(ឃុំខ្លួនថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៥)

៨- ឈ្មោះ: [redacted] ហៅ ឈិត ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ មានទីកន្លែងកំណើតនៅភូមិព្រែកហូរលិច ឃុំព្រែកហូរ ស្រុកតាខ្មៅ ខេត្តកណ្តាល និងបច្ចុប្បន្ននៅភូមិ [redacted] សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល មានឪពុកឈ្មោះ: [redacted] (រ) ម្តាយឈ្មោះ: [redacted] (ស) នៅលីវ ទោសដោយតុលាការ គ្មាន។(ឃុំខ្លួនថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៥)



Scanned by CamScanner

០៩- ឈ្មោះ [redacted] បុជា ហៅ គ្រិន ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរ សិស្ស មានទីកន្លែងកំណើតនៅភូមិព្រៃកឬស្សី ឃុំព្រៃកឬស្សី ស្រុកតាខ្មៅ ខេត្តកណ្តាល និងបច្ចុប្បន្ននៅភូមិបត្តាជី១ [redacted] ខេត្តកណ្តាល មានឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសដោយតុលាការ គ្មាន។(គេចខ្លួន)

១០- ឈ្មោះ [redacted] ប៊ុនណ្ឌិត ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរ កសិករ មានទីកន្លែងកំណើត និងបច្ចុប្បន្ននៅ [redacted] ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល មានឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសដោយតុលាការ គ្មាន។(គេចខ្លួន)

ជាប់ចោទពីបទ៖ លួច ប្រព្រឹត្តនៅមាត់ទន្លេតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥, ប្រព្រឹត្តនៅភូមិស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥, និងបទ **សមគំនិតក្នុងអំពើលួច** ប្រព្រឹត្តនៅម្តុំផ្សារព្រែកតូច ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិ **មាត្រា ២៩, មាត្រា ៣៥៣ និងមាត្រា ៣៥៦** នៃក្រមព្រហ្មទណ្ឌ ។

១១- ឈ្មោះ [redacted] ម៉ាឃ្មោ ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ មានទីកន្លែងកំណើត និងបច្ចុប្បន្ននៅ [redacted] ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល មានឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសដោយតុលាការ គ្មាន។(គេចខ្លួន)

ជាប់ចោទពីបទ៖ លួច ប្រព្រឹត្តនៅមាត់ទន្លេតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥, ប្រព្រឹត្តនៅភូមិស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥, ប្រព្រឹត្តនៅម្តុំផ្សារព្រែកតូច ឃុំព្រែកគយ ស្រុកស្អាងខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ និងប្រព្រឹត្តនៅភូមិដើមគរ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិ**មាត្រា ៣៥៣ និងមាត្រា ៣៥៦** នៃក្រមព្រហ្មទណ្ឌ ។

-ជនរងគ្រោះឈ្មោះ [redacted] ស្រីនាង ភេទស្រី អាយុ ២៨ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិចំបក់ ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ៖ **៧៣៨** ដកសស ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ៖ ១១៣២ ដកសព ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-បានឃើញដីកាដំណោះស្រាយលេខ៖ ១១៥២ ដកដស ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះ លេខ ១៩៥ ដកចត/១៥ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ របស់ប្រធានសាលាដំបូងខេត្តកណ្តាល។



Scanned by CamScanner

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ

កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥ ស្ថិតនៅមាត់ទន្លេតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល មានជនសង្ស័យឈ្មោះ [redacted] ហេងចាន់រដ្ឋា ហៅ ដា, ឈ្មោះ [redacted] កាណាន់, ឈ្មោះ [redacted] កែវពុទ្ធិ, ឈ្មោះ [redacted] សុផាន់ណា, ឈ្មោះ [redacted] ភារម្យ, ឈ្មោះ [redacted] សាមីត, ឈ្មោះ [redacted] ស៊ុណា, ឈ្មោះ [redacted] សៀងលី, ឈ្មោះ [redacted] សុផា, ឈ្មោះ [redacted] ម៉ាហ្គោ, ឈ្មោះ [redacted] ប៊ុនល្អិត, ឈ្មោះ [redacted] ហៅ ម៉ុក, ឈ្មោះ មិនា, ឈ្មោះ វៃន និងឈ្មោះ ស្មើ បានធ្វើសកម្មភាពឆក់កាបូប និងទូរស័ព្ទដៃពីជនរងគ្រោះដែលជាអ្នកដំណើរតាមផ្លូវ។ បន្ទាប់មក នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ ជនសង្ស័យទាំង១៥នាក់ដដែលបានធ្វើសកម្មភាពឆក់កាបូប និងទូរស័ព្ទដៃពីជនរងគ្រោះដែលជាអ្នកដំណើរតាមផ្លូវម្តងទៀតនៅឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល រួចមក នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ ស្ថិតនៅម្តុំផ្សារព្រែកតូច ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល មានឈ្មោះ [redacted]ម៉ាហ្គោ ឈ្មោះ [redacted] សុផា ហៅ គ្រិន ឈ្មោះ ផា ហៅ ម៉ុក ឈ្មោះ [redacted] សាមីត ហៅ បារាំង ឈ្មោះ [redacted] សៀងលី ឈ្មោះ [redacted] សុផាន់ណា ឈ្មោះ [redacted] ប៊ុនល្អិត និងឈ្មោះ វៃន បានធ្វើសកម្មភាពឆក់កាបូបរបស់ជនរងគ្រោះដែលជាអ្នកដំណើរតាមផ្លូវ ដោយមានឈ្មោះ [redacted]ហេងចាន់រដ្ឋា, ឈ្មោះ [redacted] កាណាន់, ឈ្មោះ [redacted] កែវពុទ្ធិ,ឈ្មោះ [redacted] ភារម្យ ឈ្មោះ [redacted]ស៊ុណា ឈ្មោះ ស្មើ និងឈ្មោះ មិនា ជាអ្នកសម្របសម្រួលឱ្យជនសង្ស័យដែលបានធ្វើសកម្មភាពឆក់ក្នុងការរត់គេចខ្លួន (អ្នកបិទគូថ) និងនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ ស្ថិតនៅទល់មុខសាលាខេត្តកណ្តាល ក្នុងភូមិដើមគរ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល មានឈ្មោះ [redacted] ភារម្យ, ឈ្មោះ [redacted] ម៉ាហ្គោ ឈ្មោះ មិនា និងឈ្មោះ ផា ហៅ ម៉ុក បានធ្វើសកម្មភាពឆក់កាបូប និងទូរស័ព្ទដៃរបស់ជនរងគ្រោះ ឈ្មោះ [redacted] ស្រីនាង។

## នាពេលសួរចម្លើយ

-ជនជាប់ចោទឈ្មោះ [redacted] ហេងចាន់រដ្ឋា បានឆ្លើយថា អ្នកប្រព្រឹត្តអំពើលួចជាមួយខ្លួន មានឈ្មោះ [redacted] កាណាន់, ឈ្មោះ [redacted] ម៉ាហ្គោ និង [redacted] ភារម្យ។ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥នោះ ខ្លួនពិតជាបានចេញឆក់គេនៅមុខសាលាខេត្តកណ្តាល។ កន្លងមក ពួកខ្លួនឆក់បានកាបូបលុយគេប្រហែល ០២ដងមកហើយ។ ខ្លួនសូមបញ្ជាក់ថា នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ នោះ ឈ្មោះ [redacted] ម៉ាហ្គោ បានទៅជាមួយដែរ ប៉ុន្តែមិនមែនវាជាអ្នកឆក់នោះទេ។ ខ្លួនធ្លាប់ស្គាល់ឈ្មោះ [redacted] សុផាន់ណា នោះដែរ ហើយនៅថ្ងៃទី២៣ ខែកញ្ញា នោះវាមិនបានទៅចូលរួមសកម្មភាពឆក់ជាមួយគេទេ។

-ជនជាប់ចោទឈ្មោះ [redacted] កែវពុទ្ធិ បានឆ្លើយថា នៅថ្ងៃទី២៣ ខែកញ្ញាឆ្នាំ២០១៥ ខ្លួនមិនបានចូលរួមឆក់ជាមួយគេទេ និងមិនធ្លាប់ធ្វើសកម្មភាពបិតគូថឱ្យពួកគេនោះដែរ។ ប៉ូលីសចាប់ខ្លួន ព្រោះខ្លួនអង្គុយហូបបបរជាមួយឈ្មោះ [redacted] កាណាន់ និងឈ្មោះ [redacted] សុផាន់ណា នៅបបរស ទល់មុខ នីយ៉ាម៉ង់។ ពីមុនមក ខ្លួនមិនធ្លាប់ធ្វើសកម្មភាពឆក់កាបូបគេទេ។

-ជនជាប់ចោទឈ្មោះ [redacted] កាណាន់ បានឆ្លើយថា នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ អ្នកដែលបានចេញឆក់ជាមួយខ្លួននោះ គឺមានឈ្មោះ [redacted] សៀងលី និងឈ្មោះ [redacted] ភារម្យ និងឈ្មោះ [redacted] ហេងចាន់រដ្ឋា ក្រៅពីនេះ គឺគ្មានទេ។ ខ្លួនធ្លាប់ធ្វើសកម្មភាពឆក់កាបូបគេ បានប្រហែល ០៤ដងមកហើយ។

- ជនជាប់ចោទឈ្មោះ [redacted] ស៊ុណា បានឆ្លើយថា ខ្លួនមានអាយុ ១៥ឆ្នាំ។ នៅថ្ងៃកើតហេតុថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ ខ្លួនពិតជាបានជិះម៉ូតូដើរលេងជាមួយឈ្មោះ [redacted] ហេងចាន់រដ្ឋា ហៅ ដា នៅម្តុំកោះពេជ្រ រាជធានីភ្នំពេញ ពេលត្រឡប់មកវិញ ឈ្មោះ [redacted] ហេងចាន់រដ្ឋា ហៅ ដា ឌុបខ្លួនបណ្តើរ ហើយទៅឆក់ទូរស័ព្ទគេ បានទូរស័ព្ទ Iphone 6 plus មួយគ្រឿង។ នាពេលនោះ គឺឈ្មោះ [redacted] ហេងចាន់រដ្ឋា ជាអ្នកឆក់ ដោយខ្លួនបានឃើញច្បាស់ ព្រោះខ្លួនបានជិះជាមួយឈ្មោះ [redacted] ហេងចាន់រដ្ឋា ហៅ



Scanned by CamScanner

នោះ។ បន្ទាប់មកជិះត្រឡប់មកផ្ទះសំណាក់[redacted] ម៉េង ដោយឈ្មោះ:[redacted]ហេងចាន់រដ្ឋា ចូលបន្ទប់គេ ហើយខ្លួនចូលបន្ទប់របស់ខ្លួនរៀងៗខ្លួន។ ចំពោះថ្ងៃទី១៦ ទី១៨ និងទី២២ ខែកញ្ញា ឆ្នាំ២០១៥ ខ្លួនមិនបានចូលរួមប្រព្រឹត្តជាមួយគេទេ។ ឈ្មោះ: [redacted] ហេងចាន់រដ្ឋា មិនបានចែកលុយមកឱ្យខ្លួននោះទេ ហើយក៏មិនដែលប៉ាវផឹកស៊ីអ្វីដែរ។ ខ្លួនសូមសារភាពថា នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ ខ្លួនពិតជាបានចូលរួមឆក់ជាមួយគេមែន។ ពេលនេះ ខ្លួនបានដឹងកំហុសហើយ។

-ជនជាប់ចោទឈ្មោះ: [redacted] ភារម្យ បានឆ្លើយថា នៅថ្ងៃកើតហេតុថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ វេលាប្រហែលម៉ោង ០៧ និង៣០នាទីយប់ ខ្លួនពិតជាបានទៅឆក់កាបូបគេនៅម្តុំព្រះនារាយណ៍ ទល់មុខសាលាខេត្តកណ្តាល ជាមួយឈ្មោះ:[redacted]ហេងចាន់រដ្ឋា, ឈ្មោះ:[redacted]កាណាន់ និងឈ្មោះ:[redacted] សៀងលី។ ចំពោះ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥, ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ និងថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ ខ្លួនមិនបានទៅចូលរួមឆក់កាបូបជាមួយគេទេ គឺខ្លួននៅផ្ទះរហូត។ ខ្លួនទើបតែចេញសកម្មភាពឆក់នេះលើកទី១ប៉ុណ្ណោះ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥។ពេលដែលគ្នាខ្លួនចេញឆក់បានសម្រេច គឺទៅជុំគ្នានៅផ្ទះសំណាក់ [redacted] ម៉េង។ ខ្លួនទើបតែឆក់ជាលើកទី១ប៉ុណ្ណោះ ជាមួយឈ្មោះ [redacted] ហេងចាន់រដ្ឋា, ឈ្មោះ:[redacted]កាណាន់ និងឈ្មោះ:[redacted]សៀងលី។

- ជនជាប់ចោទឈ្មោះ: [redacted]សាមីត បានឆ្លើយថា នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ នោះខ្លួនកំពុងលាងម៉ូតូ ស្រាប់តែប៉ូលីសមកចាប់ខ្លួនតែម្តង។ ខ្លួនស្គាល់តែឈ្មោះ[redacted]កាណាន់ ម្នាក់ប៉ុណ្ណោះ។ ខ្លួនមិនដែលបានលុយពីគេឆក់បាននោះទេ។ ពីមុនមក ខ្លួនធ្លាប់ឆក់ម្តង ជាមួយឈ្មោះ:[redacted] ប៊ុនល្ហិត ដោយឆក់បានទូរស័ព្ទចំនួន០១គ្រឿង។

-ជនជាប់ចោទឈ្មោះ:[redacted]ុជាន់ណា បានឆ្លើយថា ខ្លួនធ្លាប់បានស្គាល់ឈ្មោះ:[redacted] កាណាន់ តាំងពីតូចមកម្លេះ និងឈ្មោះ: [redacted]កែវពុទ្ធិ ខ្លួនស្គាល់ប្រហែល ០១ឆ្នាំហើយ។ ចំណែកឯអ្នកដែលឃាត់ខ្លួនជាមួយ ០៥នាក់ទៀត ខ្លួនមិនដែលស្គាល់ពីមុនមកទេ។ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ ខ្លួនមិនចូលរួមសកម្មភាពឆក់កាបូបជាមួយគេទេ។ ប៉ូលីសឃាត់ខ្លួនព្រោះ ខ្លួនអង្គុយហូបបបរជាមួយឈ្មោះ:[redacted] កាណាន់ និងឈ្មោះ: [redacted] កែវពុទ្ធិ នៅទល់មុខឌីយ៉ាម៉ង់ នៅវេលាម៉ោង ១២ជាងយប់ ឈានចូលថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៥។ ពីមុនមក ខ្លួនមិនដែលធ្លាប់ឆក់កាបូបជាមួយគេទេ។

-ជនជាប់ចោទឈ្មោះ:[redacted] សៀងលី៖ កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥ ខ្លួននិងគ្នារបស់ខ្លួនបានទៅឆក់កាបូបគេនៅម្តុំមាត់ទន្លេតាខ្មៅ មានគ្នា ១៥នាក់ ដែលមានឈ្មោះ:[redacted] ម៉ាហ្គោ [redacted] ស៊ុជា ហៅក្រិន ឈ្មោះ: ផា ហៅម៉ុក ឈ្មោះ:[redacted]សាមីត ហៅ បារាំង ឈ្មោះ[redacted]កាណាន់ ឈ្មោះ:[redacted] ស៊ុជាន់ណា ឈ្មោះ: [redacted]ប៊ុនល្ហិត ឈ្មោះ: រិន ឈ្មោះ: [redacted] ហេងចាន់រដ្ឋា ឈ្មោះ: [redacted] កែវពុទ្ធិ ឈ្មោះ: [redacted]ភារម្យ ឈ្មោះ: [redacted] ស៊ីណា ហៅ ស្រីខ្វច ឈ្មោះ: រស្មី និងឈ្មោះ: មិនា ដោយឆក់បានកាបូបលុយបានសម្រេច ឈ្មោះ: [redacted] ហេងចាន់រដ្ឋា ជាអ្នកឆក់។ ឆក់លើកទី២ នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ នៅម្តុំស្វាយរលំ មានគ្នាបួននាក់ដូចជា [redacted]ហេងចាន់រដ្ឋា (អ្នកឆក់) [redacted]កាណាន់, [redacted] សាមីត ហៅ បារាំង និងរូបខ្លួន។ ឆក់លើកទី៣ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ នៅស្រុកស្អាងមិនបានសម្រេចទេ ដោយនៅមានគ្នា ០៤នាក់ គឺឈ្មោះ:[redacted]ហេងចាន់រដ្ឋា , ឈ្មោះ: [redacted] សាមីត ហៅ បារាំង និងឈ្មោះ:[redacted]កាណាន់។ ចំពោះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ ខ្លួនមិនបានចូលរួមឆក់កាបូបជាមួយគេទេ ដោយខ្លួនដេកនៅផ្ទះរហូត។ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ នោះ ខ្លួនមិនបានដឹងថា នរណា ទៅឆក់កាបូបគេខ្លះនោះទេ។ មកដល់ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៥ ប៉ូលីសក៏បានទៅឃាត់ខ្លួនរូបខ្លួននៅផ្ទះ។ ក្រោយពេលឆក់បានប្រាក់ ពួកខ្លួនបានយកប្រាក់នោះទៅស៊ីផឹក មិនបានចែកលុយគ្នាទេ។ ខ្លួនធ្លាប់បានចេញឆក់ជាមួយឈ្មោះ: [redacted]ប៊ុនល្ហិត។



Scanned by CamScanner

-អំណាងចម្លើយជនរងគ្រោះឈ្មោះ [redacted] ស្រីនាង នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ បានឆ្លើយថា៖ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង ០៧និង៣០នាទីយប់ ខ្លួនបានជិះម៉ូតូជាមួយមិត្តមកពីភ្នំពេញដល់ចំណុចខាងលិចសាលាខេត្តកណ្ដាល ភូមិដើមគរ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្ដាល ក៏ស្រាប់តែមានម៉ូតូ ០២គ្រឿង មួយគ្រឿងម៉ាក SUZUKI Nex ជិះគ្នាពីរនាក់ រាងស្គម ភេទប្រុស អាយុប្រហែល ២០ឆ្នាំ ស្លៀកខោខ្លី និងមួយគ្រឿងទៀតម៉ាក SCOOPY ពណ៌ទឹកប៊ិច ផ្លាកលេខ កណ្ដាល 1S-7333 ជិះគ្នា ០២នាក់ ភេទប្រុស អាយុប្រហែល ២០ឆ្នាំ រាងស្គម ពាក់អាវខ្មៅទាំងពីរនាក់ បាននាំគ្នាជិះកៀម៉ូតូខ្លួនឱ្យដួល ហើយឆក់យកកាបូបយួរដៃពណ៌ខ្មៅ ដែលខ្លួនទុកនៅតួកណ្ដាលម៉ូតូរបស់ខ្លួនយកទៅបាត់។ នៅក្នុងកាបូបខ្លួន មានកាត ATMមួយសន្លឹក អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លងមួយសន្លឹក កាបូបលុយមួយមានលុយចំនួន ២០០០រៀល។

-សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ៖ ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ និងអំណាងចម្លើយជនរងគ្រោះ តំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់ដូចមាននៅក្នុងដីកាសន្និដ្ឋានស្ថាពរដដែល និងស្នើសុំឱ្យតុលាការពិនិត្យ និងសម្រេចផ្ដន្ទាទោសជនជាប់ចោទទៅតាមផ្លូវច្បាប់។

-សេចក្ដីសន្និដ្ឋានរបស់លោក [redacted] វាសនា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] កែវពុទ្ធិ៖ នៅក្នុងសំណុំរឿងក្ដីនេះ កូនក្ដីខ្លួនបានឆ្លើយនៅប៉ូលីស ក៏ដូចជាតំណាងអយ្យការ ក៏ដូចជាចៅក្រមស៊ើបសួរថា ខ្លួនមិនមានការពាក់ព័ន្ធនឹងអង្គហេតុថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ នោះទេ ជាពិសេស ជនជាប់ចោទដែលមានវត្តមាននៅទីនេះ ក៏ពុំបានឆ្លើយទាក់ទងនឹងកូនក្ដីខ្លួនឈ្មោះ [redacted] កែវពុទ្ធិ ដែរ។ ដូច្នេះ សូមឱ្យតុលាការពិនិត្យទៅលើស្ថានភាពជាក់ស្ដែង ដែលបញ្ជាក់ថាកូនក្ដីខ្លួនពុំពាក់ព័ន្ធនិងបទសមត់និតក្នុងអំពើលួចនេះ។ ខ្លួនស្នើសុំឱ្យតុលាការមេត្តាពិនិត្យទៅលើមាត្រា ៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ១០ នៃរដ្ឋធម្មនុញ្ញ និងសូមឱ្យតុលាការមេត្តាពិចារណា លើកលែងការចោទប្រកាន់ពីកូនក្ដីខ្លួនឈ្មោះ [redacted] កែវពុទ្ធិ។

-សេចក្ដីសន្និដ្ឋានរបស់លោកស្រី [redacted] រាសីភ័ក្ក ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ម៉ាហ្គោ៖ កូនក្ដីខ្លួន ត្រូវបានចោទប្រកាន់ពីបទ អំពើលួច ហើយបើតាមការសួរដេញដោលនាពេលសវនាការនេះ បានបញ្ជាក់ថា កូនក្ដីខ្លួនបានទៅចូលរួមជាមួយ ដោយបានជិះម៉ូតូពីក្រោយ ប៉ុន្តែកូនក្ដីខ្លួនមិនបានឆក់ទេ។ ដូច្នេះ ខ្លួនសូមឱ្យលោកចៅក្រម មេត្តាពិចារណា ឱ្យកូនក្ដីខ្លួនរួចផុតពីការចោទប្រកាន់ផង ដោយសារថា តាមចម្លើយដាក់បន្ទុកឃើញថា គាត់មានការប្រែប្រួលរហូត និងចម្លើយនាពេលសវនាការនេះទៀត ឃើញថា មិនមានភស្តុតាងណាបញ្ជាក់ថា កូនក្ដីខ្លួនបានធ្វើសកម្មភាពឆក់នោះទេ ហើយឃើញថា កូនក្ដីខ្លួនមានអាយុទើបតែ១៦ឆ្នាំប៉ុណ្ណោះ។ តាមចម្លើយជនជាប់ចោទនាពេលសវនាការនេះ ឃើញថា មិនមានការពាក់ព័ន្ធនឹងកូនក្ដីខ្លួនទេ ដូចនេះ ខ្លួនសូមឱ្យលោកប្រធាន ឱ្យកូនក្ដីខ្លួនរួចផុតពីបទចោទប្រកាន់ផង។

-សេចក្ដីសន្និដ្ឋានរបស់លោកមេធាវី [redacted] វីរៈ តាមចម្លើយសារភាពរបស់កូនក្ដីខ្លួនទាំង០៤នាក់ នៅថ្ងៃទី១៦ និង១៨ ខែកញ្ញា ពួកខ្លួន ស្ថិតនៅមាត់ទន្លេ ហើយនៅថ្ងៃទី២៣ ខែកញ្ញា សមត្ថកិច្ចបានធ្វើការព័ទ្ធចាប់ដោយពុំមានវត្ថុតាងអ្វីឡើយ ហើយនៅពេលនេះ កូនក្ដីខ្លួនបានសារភាពថា ចូលរួមសកម្មភាពឆក់លើកទី១ប៉ុណ្ណោះ។ ដូច្នេះ តាមមាត្រា ៣៨, មាត្រា ៣៩ និងមាត្រា ៤០ នៃក្រមព្រហ្មទណ្ឌ ស្នើសុំឱ្យតុលាការមេត្តាបន្ធូរ ឬលើកលែងចោទ ដើម្បីឱ្យឪពុកម្ដាយយកទៅអប់រំ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សាម៉ិត ៖ ខ្លួនសំណូមពរឱ្យតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង ព្រោះខ្លួនបានដឹងកំហុសហើយ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សុជាន់ណា៖ ខ្លួនសំណូមពរឱ្យតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង ព្រោះខ្លួនបានដឹងកំហុសហើយ។/



Scanned by CamScanner

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] កែវពុទ្ធិ ៖ ខ្លួនសំណូមពរឱ្យតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង ព្រោះខ្លួនបានដឹងកំហុសហើយ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ហេងចាន់រដ្ឋា៖ ខ្លួនសំណូមពរឱ្យតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង ព្រោះខ្លួនបានដឹងកំហុសហើយ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] កាណាន់៖ ខ្លួនសំណូមពរឱ្យតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង ព្រោះខ្លួនបានដឹងកំហុសហើយ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា៖ ខ្លួនសំណូមពរឱ្យតុលាការដោះលែងខ្លួនត្រឡប់ទៅផ្ទះវិញ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សៀងលី៖ ខ្លួនសំណូមពរឱ្យតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង ព្រោះខ្លួនបានដឹងកំហុសហើយ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ការម្យ៖ ខ្លួនសំណូមពរឱ្យតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង ព្រោះខ្លួនបានដឹងកំហុសហើយ។

ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្ដាប់អំណានចម្លើយជនរងគ្រោះ

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានស្ដាប់សំដីចុងក្រោយ និងសំណូមពររបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារនានា

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## ***សាលាដំបូងខេត្តកណ្ដាល***

## **យល់ឃើញថា**

-ជនជាប់ចោទឈ្មោះ [redacted] ហេងចាន់រដ្ឋា , ឈ្មោះ [redacted] ការម្យ,ឈ្មោះ [redacted] កាណាន់, ឈ្មោះ [redacted] ស៊ីណា ហៅ ស្រីខូច, ឈ្មោះ [redacted] កែវពុទ្ធិ, ឈ្មោះ [redacted] សុជាន់ណា, ឈ្មោះ [redacted] សៀងលី ហៅ ឈិត, ឈ្មោះ [redacted] ហាមីត ហៅ បាក់ង, ឈ្មោះ [redacted] សុជា ហៅ ក្រិន,ឈ្មោះ [redacted] ម៉ាហ្គោ, ឈ្មោះ [redacted] ប៊ុនណ្ឌិត មានស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើដែលខ្លួនប្រព្រឹត្ត ហើយក៏ពុំមានសញ្ញាណាមួយដែលអាចបញ្ជាក់ថា ជនជាប់ចោទមានបញ្ហាវិបល្លាសស្មារតីឡើយ ។

-អំពើរបស់ជនជាប់ចោទ គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិឯកជនរបស់អ្នកដទៃ របៀបរៀបរយសាធារណៈ និងសន្តិសុខសណ្ដាប់ធ្នាប់សង្គម ដែលច្បាប់បានហាមឃាត់ ហើយបានបញ្ញត្តិជាបទល្មើសព្រហ្មទណ្ឌ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហេងចាន់រដ្ឋា នាពេលសវនាការបានឆ្លើយថា គ្នាធ្វើសកម្មភាពឆក់ជាមួយខ្លួនមានឈ្មោះ [redacted] កាណាន់, [redacted] ការម្យ និងឈ្មោះ [redacted] ម៉ាហ្គោ។ ពេលចេញឆក់គឺឈ្មោះ [redacted] ម៉ាហ្គោ បានជិះពីក្រោយ ប៉ុន្តែមិនបានឆក់នោះទេ។ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ ខ្លួនមិនបានចេញធ្វើសកម្មភាពឆក់គេនោះទេ។ និងតាមចម្លើយឈ្មោះ [redacted] ហេងចាន់រដ្ឋា នៅដំណាក់កាលចៅក្រមស៊ើបសួរ បានឆ្លើយថា ខ្លួននិងមិត្តភក្តិ ធ្លាប់ធ្វើកម្មភាពឆក់ បានចំនួន០៣ លើកមកហើយ គឺនៅថ្ងៃទី១៦, ទី១៨ និងទី២២ ខែកញ្ញា ឆ្នាំ២០១៥។ នៅថ្ងៃទី១៦ និងទី១៨ ខែកញ្ញា ឆ្នាំ២០១៥ មានគ្នា ១៥នាក់ គឺមានរូបខ្លួន [redacted] ម៉ាហ្គោ [redacted] សុជា ហៅក្រិន ឈ្មោះ ធា ហៅម៉ុក ឈ្មោះ [redacted] សាមីត ហៅ



Scanned by CamScanner

បាក់ង ឈ្មោះ [redacted] សៀងលី ឈ្មោះ [redacted] សុផាន់ណា ឈ្មោះ [redacted] ប៊ុនណ្ឌិត ឈ្មោះ វៃ ឈ្មោះ [redacted] កាណាន់ ឈ្មោះ [redacted] កែវពុទ្ធិ ឈ្មោះ [redacted] ភារម្យ ឈ្មោះ [redacted] ស៊ីណា ហៅ ស្រីខូច ឈ្មោះ រស្មី និងឈ្មោះ មិនា។ ចំណែកឯនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ មានគ្នា ០៤នាក់ គឺឈ្មោះ [redacted] ឈ្មោះ ក្រិន និងឈ្មោះ [redacted] សុផាន់ណា។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] កែវពុទ្ធិ បានឆ្លើយថា ថ្ងៃទី២៣ ខែកញ្ញាឆ្នាំ២០១៥ ខ្លួនមិនបានចូលរួមឆក់ជាមួយគេទេ និងមិនធ្លាប់ធ្វើសកម្មភាពបិតគូថឱ្យពួកគេនោះដែរ។ ប៉ូលីសចាប់ខ្លួនព្រោះខ្លួនអង្គុយហូបបបរជាមួយឈ្មោះ [redacted] កាណាន់ និងឈ្មោះ [redacted] សុផាន់ណា នៅបបរសេ ទល់មុខ ឌីយ៉ាម៉ង់។ ពីមុនមក ខ្លួនមិនធ្លាប់ធ្វើសកម្មភាពឆក់កាបូបគេទេ។ ប៉ុន្តែតាមចម្លើយរបស់ឈ្មោះ [redacted] ហេងចាន់រដ្ឋា, ឈ្មោះ [redacted] កាណាន់ នៅដំណាក់កាលចៅក្រមស៊ើបសួរ បានឆ្លើយថា នៅថ្ងៃទី១៦ និងទី១៨ និងថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ គឺមានឈ្មោះ [redacted] កែវពុទ្ធិ ចូលរួមសកម្មភាពឆក់កាបូបគេជាមួយពួកខ្លួនដែរ។ ដូច្នេះ ការឆ្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] កែវពុទ្ធិ គ្មានភស្តុតាងណាមួយដែលអាចឱ្យតុលាការជឿបានឡើយ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] កាណាន់ នាពេលសវនាការបានឆ្លើយថា នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ អ្នកដែលបានចេញឆក់ជាមួយខ្លួននោះ គឺមានឈ្មោះ [redacted] សៀងលី និងឈ្មោះ [redacted] ភារម្យ និងឈ្មោះ [redacted] ហេងចាន់រដ្ឋា ក្រៅពីនេះ គឺគ្មានទេ។ ខ្លួនធ្លាប់ធ្វើសកម្មភាពឆក់កាបូបគេ បានប្រហែល ០៤ដងមកហើយ។ និងតាមចម្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ បានឆ្លើយថា ខ្លួនធ្លាប់បានចេញឆក់ចំនួន ០៤លើក គឺថ្ងៃទី១៦ ទី១៨ និងទី២២ ខែកញ្ញា ឆ្នាំ២០១៥ ដោយមានគ្នា១៥នាក់ គឺមានរូបខ្លួន [redacted] ម៉ាហ្គោ [redacted] សុផា ហៅក្រិន ឈ្មោះ ធា ហៅម៉ុក ឈ្មោះ [redacted] សាមីត ហៅ បាក់ង ឈ្មោះ [redacted] សៀងលី ឈ្មោះ [redacted] សុផាន់ណា ឈ្មោះ [redacted] ប៊ុនណ្ឌិត ឈ្មោះ វៃ ឈ្មោះ [redacted] ហេងចាន់រដ្ឋា ឈ្មោះ [redacted] កែវពុទ្ធិ ឈ្មោះ [redacted] ភារម្យ ឈ្មោះ [redacted] ស៊ីណា ហៅ ស្រីខូច ឈ្មោះ រស្មី និងឈ្មោះ មិនា និងលើកទី៤ មិនចាំ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ហៅ ស្រីខូច បានឆ្លើយថា នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ ខ្លួន ពិតជាបានចូលរួមសកម្មភាពឆក់ជាមួឈ្មោះ [redacted] ហេងចាន់រដ្ឋា ពិតមែន។ ប៉ុន្តែ ខ្លួនមិនដែលបានចំណែកលុយពីឈ្មោះ [redacted] ហេងចាន់រដ្ឋា ឡើយ។ ចំពោះថ្ងៃទី១៦ ទី១៨ និងទី២២ ខែកញ្ញា ឆ្នាំ២០១៥ ខ្លួនមិនបានចូលរួមជាមួយគេទេ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ភារម្យ បានឆ្លើយថា នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ ខ្លួនពិតជាបានធ្វើសកម្មភាពឆក់កាបូបជាមួយឈ្មោះ [redacted] ហេងចាន់រដ្ឋា,ឈ្មោះ [redacted] កាណាន់ និងឈ្មោះ [redacted] សៀងលី មែន ហើយនៅថ្ងៃទី១៦ ទី១៨ និងទី២២ ខែកញ្ញា ឆ្នាំ២០១៥ ខ្លួនមិនបានចូលរួមឆក់កាបូបជាមួយគេទេ ដែលចម្លើយនេះ គ្រាន់តែជាចម្លើយឆ្លើយដោះសារដើម្បីគេចវេសពីការទទួលខុសត្រូវប៉ុណ្ណោះ ដោយតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហេងចាន់រដ្ឋា ឈ្មោះ [redacted] កាណាន់ ឈ្មោះ [redacted] សាមីត ឈ្មោះ [redacted] សៀងលី នៅដំណាក់កាលចៅក្រមស៊ើបសួរ បានឆ្លើយថា នៅថ្ងៃទី១៦ ទី១៨ និងទី២២ ខែកញ្ញា ឆ្នាំ២០១៥ ឈ្មោះ [redacted] ភារម្យ ក៏បានចូលរួមសកម្មភាពឆក់ជាមួយក្រុមខ្លួនដែរ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សាមីត នាពេលសវនាការបានឆ្លើយថា នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ ខ្លួនមិនបានចូលរួមឆក់កាបូបជាមួយគេទេ ហើយធ្លាប់បានធ្វើសកម្មភាពឆក់ម្តងជាមួយនឹងឈ្មោះ [redacted] ប៊ុនណ្ឌិត ប៉ុន្តែតាមចម្លើយរបស់ឈ្មោះនេះ នៅដំណាក់កាលចៅក្រមស៊ើបសួរ



Scanned by CamScanner

បានឆ្លើយថា ខ្លួនធ្លាប់ធ្វើសកម្មភាពឆក់កាបូបគេបានចំនួន ០៥ដងមកហើយ លើកទី១ និងលើកទី២ មិនចាំ និងថ្ងៃទី១៦ ទី១៨ និងទី២២ ខែកញ្ញា ឆ្នាំ២០១៥។ អ្នកដែលធ្លាប់ចូលរួមធ្វើសកម្មភាពឆក់ជាមួយខ្លួនមានឈ្មោះ [redacted]កាណាន់ ឈ្មោះ[redacted]ហេងចាន់រដ្ឋា ឈ្មោះ [redacted] ភារម្យ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted]សុផាន់ណា បានឆ្លើយថា នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ ខ្លួនមិនបានធ្វើសកម្មភាពឆក់ជាមួយគេទេ ហើយពីមុនមកក៏មិនដែល ឆក់កាបូបគេដែរ។ ប៉ុន្តែបើតាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ហេងចាន់រដ្ឋា ឈ្មោះ [redacted]កាណាន់ ឈ្មោះ[redacted] សៀងលី និងឈ្មោះ [redacted]ភារម្យ នៅដំណាក់កាលចៅក្រមស៊ើបសួរ បានបញ្ជាក់ថា នៅថ្ងៃទី១៦ ទី១៨ និងទី២២ ខែកញ្ញា ឆ្នាំ២០១៥ ឈ្មោះ[redacted]សុផាន់ណា ក៏បានចូលរួមសកម្មភាពឆក់កាបូបជាមួយក្រុមខ្លួនដែរ។ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុផាន់ណា គ្រាន់តែជាចម្លើយមួយដើម្បីដោះសារឱ្យខ្លួនរួចផុតពីការទទួលខុសត្រូវចំពោះមុខច្បាប់ប៉ុណ្ណោះ គ្មានភស្តុតាង និងមូលដ្ឋានណាមួយដែលអាចឱ្យតុលាការជឿបានឡើយ។

-តាមចម្លើយជនជាប់ចោទឈ្មោះ[redacted]សៀងលី បានឆ្លើយសារភាពគ្រប់ដំណាក់កាលថា នៅថ្ងៃទី១៦ ទី១៨ និងទី ២២ ខែកញ្ញា ឆ្នាំ២០១៥ ខ្លួន និងក្រុមខ្លួន ពិតជាបានធ្វើសកម្មភាពឆក់កាបូបគេ ពិតប្រាកដមែន ប៉ុន្តែនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ ខ្លួនមិនបានចូលរួមសកម្មភាពឆក់ជាមួយគេនោះទេ។

-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីនាង បានឆ្លើយថា កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង ០៧និង៣០នាទីយប់ ខ្លួនបានជិញម៉ូតូជាមួយមិត្តមកពីភ្នំពេញដល់ចំណុចខាងលិចសាលាខេត្តកណ្ដាល ភូមិដើមគរ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្ដាល ក៏ស្រាប់តែមានម៉ូតូ ០២គ្រឿង មួយគ្រឿងម៉ាក SUZUKI Nex ជិះគ្នាពីរនាក់ រាងស្គម ភេទប្រុស អាយុប្រហែល ២០ឆ្នាំ ស្លៀកខោខ្លី និងមួយគ្រឿងទៀតម៉ាក SCOOPY ពណ៌ទឹកប៊ិច ផ្លាកលេខ កណ្ដាល 1S-7333 ជិះគ្នា ០២នាក់ ភេទប្រុស អាយុប្រហែល ២០ឆ្នាំ រាងស្គម ពាក់អាវខ្មៅទាំងពីរនាក់ បាននាំគ្នាជិះកៀរម៉ូតូខ្លួនឱ្យដួល ហើយឆក់យកកាបូបយួរដៃពណ៌ខ្មៅ ដែលខ្លួនទុកនៅតួ កណ្ដាលម៉ូតូរបស់ខ្លួនយកទៅបាត់។ នៅក្នុងកាបូបខ្លួន មានកាត ATMមួយសន្លឹក អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លងមួយសន្លឹក កាបូបលុយមួយមានលុយចំនួន ២០០០រៀល។

-តាមចម្លើយរបស់ជនជាប់ចោទ, ជនរងគ្រោះ និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ធៀបនឹងឯកសារគតិយុត្តិផ្សេងៗ ឃើញថា មានភស្តុតាង និងមានធាតុផ្សំគ្រប់គ្រាន់ បញ្ជាក់អោយឃើញថា ជនជាប់ចោទទាំងអស់នេះ ពិតជាបានប្រព្រឹត្តនូវអំពើលួច និងសមគំនិតក្នុងអំពើលួច ប្រាកដមែន ហើយជាក្រុមឆក់យ៉ាងសកម្មនៅក្រុងតាខ្មៅទៀតផង ដែលបានចេញឆក់ជាក្រុមជាច្រើនដង ហើយពេលឆក់បាន ក្រុមទាំងនេះ បានទៅជុំគ្នានៅផ្ទះសំណាក់[redacted]ម៉េង។

-សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ មានអំណះអំណាងសមហេតុផល អាចឲ្យតុលាការយកពិនិត្យ និងពិចារណាបាន ។

-មេធាវី[redacted]ពាសនា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]កែវពុទ្ធិ បានសន្និដ្ឋានស្នើសុំឱ្យតុលាការ លើកលែងការចោទប្រកាន់មកលើកូនក្ដីខ្លួន ហេតុនេះ តុលាការនឹងធ្វើការពិនិត្យពិចារណាទៅតាមអង្គហេតុ និងផ្លូវច្បាប់ជាក់ស្ដែង។

-មេធាវី [redacted] ពាសភ័ក្ត ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]ម៉ាហ្គោ បានសន្និដ្ឋានស្នើសុំឱ្យតុលាការ សម្រេចឱ្យកូនក្ដីខ្លួនរួចផុតពីបទចោទប្រកាន់។ តុលាការ យល់ឃើញថា តាមចម្លើយជនជាប់...



Scanned by CamScanner

ចោទឈ្មោះ [redacted] ហេងចាន់រដ្ឋា និងជនជាប់ចោទផ្សេងទៀត បានបញ្ជាក់ថា ឈ្មោះ [redacted] ម៉ាហ្គោ ពិតជាបានចូលរួមសកម្មភាពជក់ជាមួយក្រុមខ្លួនពិតប្រាកដមែន។ ដូច្នេះ តុលាការនឹងធ្វើការពិនិត្យពិចារណាទៅតាមអង្គហេតុ និងផ្លូវច្បាប់ជាក់ស្តែង។

-មេធាវី [redacted] វិរៈ បានសន្និដ្ឋានស្នើសុំឱ្យបន្ធូរបន្ថយទោស ឬលើកលែងចោទប្រកាន់ដល់កូនក្តីរបស់ខ្លួនផង ដូចនេះ តុលាការនឹងធ្វើការពិនិត្យពិចារណាទៅតាមផ្លូវច្បាប់ជាក់ស្តែង។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ភារម្យ ពីបទ៖ លួច ប្រព្រឹត្តនៅមាត់ទន្លេតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥, ស្ថិតនៅភូមិស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥, ប្រព្រឹត្តនៅភូមិដើមគរ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ និងបទ សមគំនិតក្នុងអំពើលួចប្រព្រឹត្តនៅម្តុំផ្សារព្រែកតូច ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញាត្តិ មាត្រា ២៩, មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] កាណាន់, ឈ្មោះ [redacted] ស៊ីណា ហៅ ស្រីខូច, ឈ្មោះ [redacted] កែវពុទ្ធិ ហៅ តាំង, ឈ្មោះ [redacted] ហេងចាន់រដ្ឋា ហៅ ដា ពីបទ៖ លួច ប្រព្រឹត្តនៅមាត់ទន្លេតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥, ប្រព្រឹត្តនៅភូមិស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ និងបទ សមគំនិតក្នុងអំពើលួច ប្រព្រឹត្តនៅម្តុំផ្សារព្រែកតូច ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញាត្តិ មាត្រា ២៩, មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សាមីត ហៅ បារាំង, ឈ្មោះ [redacted] សៀងលី ហៅ ឈិត, ឈ្មោះ [redacted] ន់ណា, ឈ្មោះ [redacted] សុជា ហៅ ក្រិន, ឈ្មោះ [redacted] ប៊ុនល្អិត ពីបទ៖ លួច ប្រព្រឹត្តនៅមាត់ទន្លេតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥, ប្រព្រឹត្តនៅភូមិស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥, និងបទ សមគំនិតក្នុងអំពើលួច ប្រព្រឹត្តនៅម្តុំផ្សារព្រែកតូច ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញាត្តិ មាត្រា ២៩, មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ម៉ាហ្គោ ពីបទ លួច ប្រព្រឹត្តនៅមាត់ទន្លេតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥, ប្រព្រឹត្តនៅភូមិស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥, ប្រព្រឹត្តនៅម្តុំផ្សារព្រែកតូច ឃុំព្រែកគយ ស្រុកស្អាងខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ និងប្រព្រឹត្តនៅភូមិដើមគរ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញាត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

-ជនជាប់ចោទឈ្មោះ [redacted] ភារម្យ, ឈ្មោះ [redacted] ស៊ីណា, ឈ្មោះ [redacted] សៀងលី និងឈ្មោះ [redacted] ម៉ាហ្គោ ជាអនីតិជនមានអាយុ ១៨ឆ្នាំ និងក្រោម ១៨ឆ្នាំ ហេតុនេះ គប្បីតុលាការធ្វើការពិចារណាពីការផ្តន្ទា



Scanned by CamScanner

ទោសលើជនជាប់ចោទទាំង០៤នាក់នេះ ដោយឱ្យអនុវត្តទោសពាក់កណ្តាលនៃនីតិជន តាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

-វត្ថុតាងរួមមាន ម៉ូតូចំនួនមួយគ្រឿងម៉ាក SUZUKI NEX ពណ៌ស ផ្លាកលេខ ភ្នំពេញ 1DD-1897 គ្មានកូនសោរ ជាមធ្យោបាយប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូសទុកជាសម្បត្តិរដ្ឋ។ ចំពោះវត្ថុតាង ម៉ូតូចំនួនមួយគ្រឿងម៉ាក SCOOPY ពណ៌ខៀវ ស្លាកលេខ កណ្តាល 1S-7333 ជាកម្មសិទ្ធិរបស់គតិយជន ហើយត្រូវបានចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្តាល បានចេញដីកាសម្រេចប្រគល់ម៉ូតូឱ្យឈ្មោះ[redacted] ឡេម ភេទស្រី អាយុ ៤៦ឆ្នាំ តាមដីកាសម្រេចប្រគល់លេខ ៥៦៦ ដកសប ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥រួចហើយ។

- ជនរងគ្រោះឈ្មោះ [redacted] ស្រីនាង បានអវត្តមានតាមកាលកំណត់កោះហៅរបស់តុលាការតាំងពីដំណាក់កាលចៅក្រមស៊ើបសួរ ក៏ដូចជាចៅក្រមជំនុំជម្រះ ហើយក៏មិនបានប្តឹងសុំទាមទារសំណងពីជនជាប់ចោទឡើយ ហេតុដូច្នេះ តុលាការមិនធ្វើការពិចារណាទៅលើសំណងរដ្ឋប្បវេណីដល់ជនរងគ្រោះឡើយ។

-ជនជាប់ចោទឈ្មោះ [redacted] សុជា ហៅ ក្រិន, ឈ្មោះ [redacted]ម៉ាហ្គោ និងឈ្មោះ [redacted] ប៊ុនល្ហិត ត្រូវបានចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្តាល ចេញដីកាបង្គាប់ឱ្យចាប់ខ្លួន កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥រួចហើយ។

## <u>ហេតុដូច្នេះសម្រេច</u>

១-ផ្តន្ទាទោស៖

១.១.ឈ្មោះ[redacted]ហងចាន់រដ្ឋា ហៅ ដា ភេទប្រុស អាយុ១៨ឆ្នាំ, ឈ្មោះ[redacted]កែវពុទ្ធិ ហៅ តាំង ភេទប្រុស អាយុ ២០ឆ្នាំ និង ឈ្មោះ[redacted]កាណាន់ ភេទប្រុស អាយុ ១៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ០២ (ពីរ)ឆ្នាំ

១.២.ឈ្មោះ[redacted]ស៊ីណា ហៅ ស្រីខូច ភេទស្រី អាយុ ១៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ០១ (មួយ) ឆ្នាំ

ពីបទ៖ លួច ប្រព្រឹត្តនៅមាត់ទន្លេតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥, ប្រព្រឹត្តនៅភូមិស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ និងបទ សមគំនិតក្នុងអំពើលួច ប្រព្រឹត្តនៅម្តុំផ្សារព្រែកតូច ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ២៩, មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

១.៣.ឈ្មោះ [redacted] ភារម្យ ភេទប្រុស អាយុ ១៦ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន០១ (មួយ) ឆ្នាំ ពីបទ៖ លួច ប្រព្រឹត្តនៅមាត់ទន្លេតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥, ប្រព្រឹត្តនៅភូមិស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥, ប្រព្រឹត្តនៅភូមិដើមគរ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ និងបទ សមគំនិតក្នុងអំពើលួច ប្រព្រឹត្តនៅម្តុំផ្សារព្រែកតូច ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ២៩, មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

១.៤.ឈ្មោះ[redacted]សាមិត ហៅ បារាំង ភេទប្រុស អាយុ ១៩ឆ្នាំ, ឈ្មោះ[redacted]សុផាន់ណា ភេទប្រុស អាយុ ២១ឆ្នាំ, ឈ្មោះ [redacted] សុជា ហៅ ក្រិន ភេទប្រុស អាយុ ១៩ឆ្នាំ និងឈ្មោះ[redacted]ប៊ុនល្ហិត ភេទប្រុស អាយុ ១៩ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ០២ (ពីរ) ឆ្នាំ ✓



Scanned by CamScanner

១.៥.ឈ្មោះ [redacted] សៀងលី ហៅ ឈិត ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន០១ (មួយ) ឆ្នាំ

ពីបទ៖ លួច ប្រព្រឹត្តនៅមាត់ទន្លេតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥, ប្រព្រឹត្តនៅភូមិស្វាយរលំ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥, និងបទ សមគំនិតក្នុងអំពើលួច ប្រព្រឹត្តនៅម្តុំផ្សារព្រែកតូច ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ២៩, មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

១.៦. ឈ្មោះ [redacted] ម៉ាហ្គោ ភេទប្រុស អាយុ ១៦ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ០១ (មួយ) ឆ្នាំ ពីបទ៖ លួច ប្រព្រឹត្តនៅមាត់ទន្លេតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ ២០១៥, ប្រព្រឹត្តនៅភូមិស្វាយរលំ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥, ប្រព្រឹត្តនៅម្តុំផ្សារព្រែកតូច ឃុំព្រែកគយ ស្រុកស្អាងខេត្តកណ្ដាល កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ និងប្រព្រឹត្តនៅភូមិដើមគរ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

២-រឹបអូស ម៉ូតូចំនួនមួយគ្រឿងម៉ាក SUZUKI NEX ពណ៌ស ផ្លាកលេខ ភ្នំពេញ 1DD-1897 គ្មានកូនសោរ ទុកជាសម្បត្តិរដ្ឋ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នាថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈ នាថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហេងចាន់រដ្ឋា ហៅ ដា, ឈ្មោះ [redacted] កែវពុទ្ធិ ហៅ តាំង, ឈ្មោះ [redacted] កាណាន់, ឈ្មោះ [redacted] ស៊ីណា ហៅ ស្រីខូច, ឈ្មោះ [redacted] ភារម្យ, ឈ្មោះ [redacted] សាមីត ហៅ បាក់ង, ឈ្មោះ [redacted] សុជាន់ណា និងឈ្មោះ [redacted] សៀងលី ហៅឈិត និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សុជា ហៅ គ្រិន, ឈ្មោះ [redacted] ប៊ុនណ្ឌិត និងឈ្មោះ [redacted] ម៉ាហ្គោ ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា

[redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា

[redacted]

---

(បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម)

កណ្ដាល, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned by CamScanner